ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាជំនុំព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤០

ចុះថ្ងៃទី០១ខែតុលាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៧

ចុះថ្ងៃទី១៩ខែឧសភាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណ: នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៩

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ឃឹម ស៊ីផល ចៅក្រមរបាយការណ៍

៣- លោក ប្រាក់ គឹមសាន ចៅក្រម

៤- លោក សោម សិរីវឌ្ឍ ចៅក្រម

៥- លោក យស់ សួខឿន ចៅក្រម

ក្រឡាបញ្ជី

លោក ទេព ទាន់ថា

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤០ ចុះថ្ងៃទី ០១ ខែ តុលាឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

ពីបទ : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៩-០៥-៩៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រាទី ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-០៩-៩២ ។

- ជនជាប់ចោទឈ្មោះ តាំង ណៃ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ មុខរបរបោកអ៊ុត ទីលំនៅ ផ្ទះលេខ ៥៩អ៊ី២ ផ្លូវលេខ ១៣០ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ តាំង ហ៊ុន "ស" ម្តាយឈ្មោះ ហុង គី "រ" ប្តីឈ្មោះ អៀ ម៉េងឃាង មានកូន ០៤នាក់ ទោសពីមុនគ្មាន ។

មេធាវី ឬ អ្នកការពារ គ្មាន ។

- ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ លី អ៊ុយ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៥១ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅផ្ទះលេខ ១៨១អ៊ី១ ផ្លូវស៊ីសុវត្ថិ

សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ លី វៀន "ស" ម្តាយឈ្មោះ ផុង អ៊ីយហ៊ាង "ន" ប្រពន្ធឈ្មោះ សុខ ខេង មានកូន ០៣ នាក់ ។

មេធាវី ឬ អ្នកការពារ គ្មាន ។

តាមពាក្យបណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ តាំង ង៉ែ ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ១៩៩៧ របស់ឈ្មោះ លី អ៊ុយ ប្តឹងពីឈ្មោះ តាំង ង៉ែ ដោយសំអាងថា កាលពីថ្ងៃទី ០៩-០៥-៩៧ ឈ្មោះតាំងង៉ែ បានប្រើល្បិចថា: ខ្ចីប្រាក់ តែបីម៉ោង ដើម្បីកាត់អីវ៉ាន់ពីគេ រួចហើយសងវិញ ។ ក្រោយពីបានបីម៉ោងហើយខ្លួនបានទៅទារវិញ ស្រាប់តែឈ្មោះ តាំង ង៉ែ ថា : ប្រាក់នេះត្រូវគេប្លន់ខ្លួនបន្តទៀត ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញនៅពេលសវនាការថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ តាំង ង៉ែ ពីបទរំលោភលើសេចក្តីទុកចិត្ត កាលពីថ្ងៃទី ០៩-០៥-៩៧ ប្រព្រឹត្តនៅក្រុងភ្នំពេញពិតប្រាកដមែន ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រាទី ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយសំរេចតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១០៦៥ ចុះថ្ងៃទី ០៤-០៨-៩៧ ទុកជាបានការពេញលេញតទៅ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨១ "ឃ" ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១- ផ្តន្ទាទោសឈ្មោះ តាំង ង៉ែ ភេទស្រី អាយុ ៤៧ ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា ដាក់ពន្ធនាគារចំនួនមួយ "០១" ឆ្នាំ តែទោសនេះអនុវត្តនៅពន្ធនាគារចំនួនប្រាំមួយ "០៦" ខែ គិតចាប់តាំងពីសាលក្រមចូលជាស្ថាពរ និង ព្យួរទោសចំនួនប្រាំមួយ "០៦" ខែ ក្នុងរយៈពេលសាកល្បងចំនួនប្រាំ "០៥" ឆ្នាំ គិតចាប់តាំងពីទណ្ឌិតចេញពីពន្ធនាគារ តាមមាត្រាទី ៤៦ និង មាត្រាទី ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បង្គាប់អោយឈ្មោះ តាំង ង៉ែ សងប្រាក់ចំនួនមួយម៉ឺនដុល្លារអាមេរិក "១០.០០០ដុល្លារគត់" និង ជម្ងឺចិត្តមួយពាន់ដុល្លារអាមេរិក "១.០០០ដុល្លា" ទៅអោយ លីអ៊ុយ វិញ គិតចាប់តាំងពីសាលក្រមចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតខាងលើគ្មានទ្រព្យសម្បត្តិសងនូវទណ្ឌគ្រប់ចំនួន ត្រូវដាក់គុកបង្ខំដល់រូបកាយចំនួនពីរ "០២" ឆ្នាំ តាមមាត្រាទី ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣- រឹបអូសប្រាក់ធានាចំនួនមួយពាន់ដុល្លារអាមេរិក "១០០០អ៊ុយអែស" គ្រឿងបន្លាស់ជួសជុលវិទ្យុចំនួនប្រាំកញ្ចប់ និង ផ្ទះលេខ ៥៩អឺ២ ផ្លូវ ១៣០ ក្រុម ១៦ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ

ក្រុងភ្នំពេញ ដើម្បីយកធានាសំណងរដ្ឋប្បវេណី អោយទៅឈ្មោះ លីស៊ុយ វិញ គិតចាប់ពីសាលក្រម ចូលជាស្ថាពរ ។

៤- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ជនជាប់ចោទ មេធាវីការពារ ជនជាប់ចោទ និង ជនរងគ្រោះ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ពីរ "១២" ខែ គិតចាប់តាំងពីថ្ងៃនេះ តទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៨ "ឃ" ចុះថ្ងៃទី ០៥-១១-៩៧ របស់ឈ្មោះតាំង ឃែ ប្តឹងមិនសុខចិត្ត នឹងសេចក្តីសំរេចទាំងមូលនៃសាលក្រមព្រហ្មទណ្ឌលេខ ៨១ "ឃ" ចុះថ្ងៃទី ០៤-១១-៩៧របស់តុលាការក្រុង ភ្នំពេញ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ : សុំអោយតុលាការសំរេច តម្កល់សាលក្រមរបស់តុលាការថ្នាក់ក្រោម ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៧០ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ១៩៩៨ សំរេចចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ដែលមានខ្លឹមសារដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ តាំង ឃែ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ "ឃ" ចុះថ្ងៃទី ០៤-១១-៩៧ របស់តុលាការក្រុងភ្នំពេញទុកជា បានការពេញទាំងមូល ។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខ ជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់លេខ ០៥ ចុះថ្ងៃទី ០៨-០៥-៩៨ របស់ឈ្មោះ តាំង ឃែ ប្តឹងទាស់នឹងសាល ដីកាព្រហ្មទណ្ឌលេខ ៧០ ចុះថ្ងៃទី ០២-០៤-៩៨ គ្រប់ចំណុចនៃសេចក្តីទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ០៨-០៥-៩៨ របស់ឈ្មោះ តាំង ឃែ ទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ ៧០ ចុះថ្ងៃទី ០២-០៤-៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការ ផងដែរ ដោយគ្រាន់តែកែប្រែចំណុចទី ១ នៃសេចក្តីសំរេចរបស់សាលក្រមពីទោសគុក ៦ ខែ និងទោសព្យួរ ៦ខែ មកជាទោសព្យួរទាំងអស់ ។

៣- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹង រដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ២១-០៨-១៩៩៨ របស់ឈ្មោះ តាំង ឃែ ប្តឹងមិនសុខចិត្ត នឹងសេចក្តីសំរេចទាំងមូល នៃសាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦-០៦-៩៨ របស់សាលាឧទ្ធរណ៍ ។

- បានឃើញសារណាចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ១៩៩៨ របស់ឈ្មោះ តាំង ង៉ែ ជាម្ចាស់បណ្តឹងសាទុក្ខតើទៀងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ឈ្មោះ លី អ៊ិយ និង ប្រពន្ធឈ្មោះ សុខ ខេង ជាចុងបណ្តឹងសាទុក្ខតើទៀងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ថា : មានពិរុទ្ធនល្មម លើឈ្មោះ តាំង ង៉ែ ភេទស្រី អាយុ ៥៥ ឆ្នាំ ពីបទ : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ០៤-០៥-៩៧ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រាទី ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មហាអយ្យការអមតុលាការកំពូល សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតម្កល់សាលដីកាលេខ ១៥៦ ចុះថ្ងៃទី ២៦-០៦-៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ តាំង ង៉ែ ជាម្ចាស់បណ្តឹងសាទុក្ខនាពេលសវនាការ ថា : ខ្លួនពុំដែលស្គាល់ឈ្មោះ លី អ៊ិយ ទេ ។ នៅពេលដែលខ្លួនបានដឹងខ្លួនពីគេដាក់ថ្នាំស្ពឹក ស្រាប់តែខ្លួនកំពុងនៅលើផ្ទះរបស់ឈ្មោះ លី ទៀង និង លី អ៊ិយ ។ ហេតុអ្វីក៏ឈ្មោះ លី ទៀង នឹងថា ខ្លួនរស់នៅមាត់ទន្លេ ? នេះជាល្បិចរបស់ឈ្មោះ លី ទៀង ជាអ្នកប្រឌិត ។ ក្នុងការខ្ចីប្រាក់ច្រើនយ៉ាងនេះ ម្តេចមិនធ្វើកិច្ចសន្យា ។ ហេតុនេះខ្លួនសូមតុលាការកំពូលជួយរកយុត្តិធម៌ផង ។

- បានស្តាប់ចម្លើយដោះសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុខ ខេង ជាប្រពន្ធរបស់ឈ្មោះ លី អ៊ិយ ជាចុងបណ្តឹងសាទុក្ខនាពេលសវនាការថា : ឈ្មោះ តាំង ង៉ែ និង លី ទៀង ជាសាច់ឈាមគ្នា ពុំដូចពាក្យដែលឈ្មោះ តាំង ង៉ែ និយាយនោះឡើយ ។ ឈ្មោះ លី ទៀង ជាអ្នកជូនឈ្មោះ តាំង ង៉ែ ទៅខ្ចីប្រាក់ពីឈ្មោះ លី អ៊ិយ ។ នៅពេលប្រគល់ប្រាក់ឈ្មោះ លី អ៊ិយ ពុំបានធ្វើកិច្ចសន្យាទេ ព្រោះឈ្មោះ តាំង ង៉ែ ឆ្លើយថា ពុំចាំបាច់ធ្វើអ្វីទេ គឺខ្លួនខ្ចីតែ ២ ឬ ៣ ម៉ោងប៉ុណ្ណោះ ។ ខ្លួនសូមតុលាការកំពូលសំរេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ និង របស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ តាំង ង៉ែ ជាម្ចាស់បណ្តឹងសាទុក្ខ តើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា តាមចម្លើយសាក្សី អ្នកស្រី តាំង វ៉ែន ពិតជាបានទទួលលុយពីលោកលី អ៊ុយ ដោយកិច្ចសន្យាផ្ទាល់មាត់ពិតប្រាកដមែន ពីព្រោះថា ៖ អ្នកទាំងសងខាងសុទ្ធតែជាសាច់ញាតិ មានការជឿទុកចិត្តគ្នា និងគន្លងមកអ្នកស្រីធ្លាប់តែខ្ចីលុយពីអ្នកស្រី លី ទៀង ដោយផ្ទាល់មាត់ ហើយមានសាក្សីដឹងឮទៀតផង ។

- យល់ឃើញថា ចម្លើយកូនស្រីបង្កើតរបស់អ្នកស្រីឈ្មោះ អ៊ា ចៅជីញ និង ចៅអេង បានឆ្លើយនៅសវនាការតុលាការក្រុងភ្នំពេញថា "ពេលមកដល់ផ្ទះ ម្តាយរបស់នាងខ្ញុំមានសភាព តម្នតា ពុំមានសន្លប់ ឬ បាត់បង់ស្មារតីទេ ហើយខ្លួនបានព្យាយាមខ្លួននិយាយទៅកាន់អ្នកស្រី ជី ទៀង ថា ៖ គាត់នឹងសងលុយនេះវិញ នៅពេលគាត់រកប្រាក់បាន" ។

- យល់ឃើញថា រាល់ចម្លើយ និង វត្ថុតាងជាប់នឹងខ្លួនអ្នកស្រី បានបញ្ជាក់ច្បាស់ថា អ្នកស្រី តាំង វ៉ែន បានខ្ចីលុយចំនួនមួយម៉ឺនដុល្លារអាមេរិកពីលោក លី អ៊ុយ កំណត់តែបីខែម្តងដើម្បីកាត់ដេរ៉ាន់ ពិតប្រាកដមែន ប៉ុន្តែដោយគ្មានលិខិតកិច្ចសន្យាជាលាយល័ក្ខអក្សរ អ្នកស្រីមានចេតនាទុច្ចរិតប្រែក្រឡះថា ខ្លួនមិនបានខ្ចីលុយ មិនដែលស្គាល់លោកលី អ៊ុយ និងមិនមែនជាបងប្អូនគ្នាទេ ។

- យល់ឃើញថា អ្នកស្រី តាំង វ៉ែន មានចេតនាទុច្ចរិត មិនគោរពកាតព្វកិច្ចក្នុងការ អនុវត្តកិច្ចសន្យារបស់ខ្លួនដោយអសុទ្ធចិត្ត គឺបានខិតខំដោះសារដើម្បីគេចវេះពីសងលុយកាក់របស់លោក លី អ៊ុយ ធ្វើអោយខូចប្រយោជន៍ដល់ម្ចាស់លុយ និងដល់អ្នកស្រី លី ទៀង ដែលជាអ្នកជួយនិយាយអោយបានខ្ចី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អ្នកស្រីតាំង វ៉ែន ពិតជាបានប្រព្រឹត្ត បទល្មើសរំលោភលើសេចក្តីទុកចិត្តកាលពីថ្ងៃទី០៨ខែឧសភាឆ្នាំ១៩៩៧ នៅក្រុងភ្នំពេញ ប្រាកដមែន បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦-៦-១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ និង គតិច្បាប់ គប្បីតម្កល់សាលដីកានេះ ទុកជាបានការពេញទាំងមូល ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទ ឈ្មោះ តាំង វ៉ែន ជាម្ចាស់បណ្តឹងសាទុក្ខទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៤៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ។